**សុន្ទរកថា**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**ថ្លែងក្នុង**

**ពិធីផ្សព្វផ្សាយដាក់ឱ្យអនុវត្តផ្លូវការ នូវ**

**«យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកាត់ដេរ ផលិតស្បែកជើង និង កាបូបកម្ពុជា ២០២២-២០២៧»**

ថ្ងៃទី ២១ ខែ មីនា ឆ្នាំ ២០២២ រាជធានីភ្នំពេញ (តាមរយៈប្រព័ន្ធវីដេអូ)

- ***ឯកឧត្តម, លោកជំទាវ, អ្នកឧកញ៉ា, ឧកញ៉ា, លោក, លោកស្រី;***
- ***សមាជិក, សមាជិកា នៃអង្គពិធីជាទីមេត្រី!***

ថ្ងៃនេះ, ខ្ញុំមានកិត្តិយស និង សេចក្តីសោមនស្សយ៉ាងក្រៃលែង ដោយបានទទួលការអនុញ្ញាតដ៏ខ្ពង់ខ្ពស់បំផុត ពីសំណាក់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ធ្វើជាអធិបតី ក្នុងពិធីផ្សព្វផ្សាយដាក់ឱ្យអនុវត្តផ្លូវការ នូវ **«យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកាត់ដេរ ផលិតស្បែកជើង និង កាបូបកម្ពុជា ២០២២-២០២៧»** ។ ខ្ញុំសូមសម្តែងនូវការស្វាគមន៍យ៉ាងកក់ក្តៅ ជូនចំពោះ **ឯកឧត្តម, លោកជំទាវ, អ្នកឧកញ៉ា, ឧកញ៉ា, លោក, លោកស្រី** ជាថ្នាក់ដឹកនាំ, មន្ត្រីរាជការ និង បណ្តាតំណាងដៃគូអភិវឌ្ឍន៍, សមាគមជាតិ-អន្តរជាតិ, សហជីព, ម្ចាស់រោងចក្រ, ម្ចាស់ម៉ាកផលិត-ផល និង អ្នកបញ្ជាទិញ ដែលបានកំពុងចូលរួមនៅក្នុងកម្មវិធី នាពេលនេះ ។

ការដាក់ឱ្យអនុវត្តឯកសារយុទ្ធសាស្ត្រសម្រាប់ **វិស័យកាត់ដេរ ផលិតស្បែកជើង និង កាបូបកម្ពុជា** ឬហៅកាត់ខ្លីថា **«វិស័យកាត់ដេរ»** ជាកិច្ចការអាទិភាពមួយរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីផ្តល់ជាផែនទីបង្ហាញផ្លូវ សម្រាប់ភាគីពាក់ព័ន្ធរួមគ្នាជំរុញការអភិវឌ្ឍវិស័យកាត់ដេរ, ដែលស្របតាមការចង្អុលបង្ហាញនៃ «**យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី ៤ ក្នុងចតុកោណទី ២**

**ស្តីពីការធ្វើពិពិធកម្មសេដ្ឋកិច្ច**» និង «**ក្របខណ្ឌយុទ្ធសាស្ត្រ និង កម្មវិធីស្តារ និង ជំរុញកំណើនសេដ្ឋកិច្ចកម្ពុជា ក្នុងការរស់នៅជាមួយកូវីដ-១៩ តាមគន្លងប្រក្រតីភាពថ្មីសម្រាប់ឆ្នាំ ២០២១-២០២៣**» ផងដែរ ។

ជាមួយគ្នានេះ, បន្ថែមលើបទអន្តរាគមន៍របស់ឯកឧត្តម **ប៉ាន សូរស័ក្តិ** រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និង ឯកឧត្តមបណ្ឌិត **អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងការងារ និង បណ្តុះ-បណ្តាលវិជ្ជាជីវៈ ព្រមទាំងចំណាប់អារម្មណ៍របស់ឧកញ៉ា **គង់ សាង** ប្រធានសមាគមរោង-ចក្រកាត់ដេរនៅកម្ពុជា, ក្នុងនាមជាតួអង្គពាក់ព័ន្ធផ្ទាល់ក្នុងវិស័យកាត់ដេរ, ខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះការចូលរួមជាពុទ្ធិ និង ទស្សនវិស័យ ប្រកបដោយភាពប្រាកដនិយម ជាពិសេស ការប្តេជ្ញាក្នុងការចូលរួមអនុវត្តយុទ្ធសាស្ត្រនេះ និង សម្រេចឱ្យបានជោគជ័យជាផ្លែផ្កា ។ លើសពីនេះ, ខ្ញុំក៏សូមសម្តែងនូវអំណរគុណ ដល់តួអង្គពាក់ព័ន្ធសំខាន់ៗផ្សេងទៀត ដែលបានចូលរួមផ្តល់ជាតុ-ចូល និង ពិគ្រោះយោបល់យ៉ាងជិតស្និទ្ធ ក្នុងការរៀបចំយុទ្ធសាស្ត្រនេះ រហូតបានបញ្ចប់ និង ទទួលបានការអនុម័តជាផ្លូវការនាពេលថ្មីៗនេះ។

## ***ឯកឧត្តម, លោកជំទាវ, អ្នកឧកញ៉ា, ឧកញ៉ា, លោក, លោកស្រី!***

ផ្អែកលើមូលដ្ឋាននៃសុខសន្តិភាព និង ស្ថិរភាពនយោបាយ, វិស័យកាត់ដេរបានរួមចំណែកយ៉ាងខ្លាំងក្លាដល់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចកម្ពុជា ក្នុងរយៈពេលជាងពីរទសវត្សរ៍កន្លងមកនេះ ដោយបានទាក់ទាញទុនវិនិយោគពីបរទេស, បង្កើតការងារ, និង ជំរុញកំណើនសេដ្ឋកិច្ចជាតិ, ជាពិសេស បាន និង កំពុងដើរតួយ៉ាងសំខាន់ សម្រាប់ការនាំចេញផលិតផលរបស់កម្ពុជា ។ ចាប់តាំងពីចុងទសវត្សរ៍ឆ្នាំ ១៩៩០ រហូតដល់ឆ្នាំ ២០០៨, វិស័យកាត់ដេរបានរួមចំណែកប្រមាណ **៩៥%** និង បន្ទាប់ពីវិបត្តិហិរញ្ញវត្ថុសកលឆ្នាំ ២០០៩ មកដល់បច្ចុប្បន្ន, វិស័យនេះនៅបន្តឈរនៅលំដាប់ទីមួយ ពោលគឺ រួមចំណែកជាមធ្យមជាង **៧០%** នៃការនាំចេញសរុបរបស់កម្ពុជា ខណៈដែលកម្ពុជាបាន និង កំពុងធ្វើពិពិធកម្មការនាំចេញផលិតផលផ្សេងទៀត ដូចជា កង់, គ្រឿងបន្លាស់រថយន្ត និង គ្រឿងបង្គុំអេឡិចត្រូនិក ជាដើម ។ ទន្ទឹមនេះ, ក្រោមប្រព័ន្ធអនុគ្រោះពន្ធទូទៅ (GSP) ដែលកម្ពុជាទទួលបាននៅឆ្នាំ ២០១៦, វិស័យនេះបានបង្ហាញចលនាការល្អ ដោយសម្រេចបានកំណើនខ្ពស់នៃការនាំចេញ និង ការធ្វើពិពិធកម្មផលិតផល តាមរយៈការកើនឡើងនូវការនាំចេញផលិតផលធ្វើដំណើរ ដូចជា វ៉ាលីស, កាបូបស្ពាយ, កាបូបយួរដៃ និង កាបូបលុយ ។ល។ ទៅកាន់ទីផ្សារសហរដ្ឋអាមេរិក ។

ក្នុងរយៈពេលមធ្យម និង វែង, វិស័យកាត់ដេរនឹងនៅតែបន្តជាចន្ទល់កំណើនសេដ្ឋកិច្ចមួយប្រកបដោយសក្តានុពល តាមរយៈការពង្រីក និង ពង្រឹងមូលដ្ឋានឧស្សាហកម្មក្នុងស្រុកសម្រាប់ការនាំចេញ និង ការចូលរួមតភ្ជាប់សេដ្ឋកិច្ចជាតិទៅនឹងខ្សែច្រវាក់តម្លៃតំបន់ និងសកល, ដោយឈរលើកត្តាឧត្តមភាពប្រកួតប្រជែងមួយចំនួន ជាពិសេស (១).ប្រាក់ឈ្នួល និង ថ្លៃផលិតកម្មប្រកួតប្រជែង, (២).ប្រព័ន្ធអនុគ្រោះផ្នែកពាណិជ្ជកម្ម និង (៣).បរិយាកាសវិនិយោគអំណោយផល ជាដើម ជាក់ស្តែង, ក្នុងរយៈពេល ៥ ឆ្នាំចុងក្រោយនេះ, តម្លៃបន្ថែមរបស់វិស័យកាត់ដេរ មានចំណែកប្រមាណ **១១ % នៃ ផលិតផលក្នុងស្រុកសរុប (ផ.ស.ស.)** ហើយគិតត្រឹម ឆ្នាំ ២០២១ ជាទិន្នន័យស្តុក, វិស័យនេះបានស្រូបយកទុនវិនិយោគប្រមាណជាង **៧ ពាន់លានដុល្លារអាមេរិក** ដែលស្មើនឹងប្រមាណ **១៧%** នៃការវិនិយោគផ្ទាល់ពីបរទេសសរុបនៅកម្ពុជា និង បានចូលរួមទ្រទ្រង់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋកម្ពុជា យ៉ាងហោចណាស់ពី **២,៥ ទៅ ៣ លាននាក់** ដែលកំពុងអាស្រ័យផល, ទាំងដោយផ្ទាល់ និង ដោយប្រយោល ។

ការរីកចម្រើន និង ការចូលរួមជាសារវន្តរបស់វិស័យកាត់ដេរ ក្នុងដំណើរការនៃកិច្ច-អភិវឌ្ឍន៍ជាតិ គឺជាសមិទ្ធផលជាក់ស្តែងនៃកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល តាមរយៈការលើកកម្ពស់បរិយាកាសវិនិយោគ និង ការដាក់ចេញគោលនយោបាយគាំទ្រនានា ។ ទោះជាយ៉ាងនេះក្តី, រចនាសម្ព័ន្ធនៃវិស័យកាត់ដេរនៅមិនទាន់មានការផ្លាស់ប្តូរគួរឱ្យកត់សម្គាល់នៅឡើយ ដោយសារៈ (១)-វិស័យកាត់ដេរបន្តស្ថិតនៅជាមជ្ឈមណ្ឌលផលិតកម្មមានតម្លៃបន្ថែមទាបនៅឡើយ និង (២)-កម្រិតសមាហរណកម្មនៃឧស្សាហកម្មគាំទ្រ ក្នុងខ្សែច្រវាក់ផ្គត់ផ្គង់ និង ខ្សែច្រវាក់តម្លៃក៏នៅមានកម្រិត ។ ជាមួយគ្នានេះ, វិស័យកាត់ដេរក៏កំពុងបន្តជួបប្រទះបញ្ហាប្រឈមមួយចំនួន ដែលមានលក្ខណៈជារចនាសម្ព័ន្ធផងដែរ ។ ផ្សារភ្ជាប់ទៅនឹងបញ្ហាប្រឈមទាំងនេះ, ក៏មាននិន្នាការ និង ការវិវត្តសំខាន់ៗក្នុងវិស័យនេះគួរឱ្យកត់សម្គាល់ ជាពិសេសពាក់ព័ន្ធនឹងកិច្ចគាំពារបរិស្ថាន ឬចីរភាពបរិស្ថាន ដែលទាមទារឱ្យមានការយកចិត្តទុកដាក់បន្ថែម, ទាំងក្នុងកម្រិតគោលនយោបាយ និង កម្រិតប្រតិបត្តិការ ។

ដោយជ្រាបច្បាស់ពីសារៈសំខាន់នេះនៃវិស័យនេះ, **សម្តេចតេជោនាយករដ្ឋមន្ត្រី** តែងផ្តល់នូវការយកចិត្តទុកដាក់ជាពិសេសដល់វិស័យកាត់ដេរ ដោយបានចុះជួបសំណេះ-សំណាល និង ស្វែងយល់ពីសុខទុក្ខជាមួយកម្មករ-និយោជិតយ៉ាងជាប់លាប់ នៅតាមបណ្តា រោងចក្រ-សហគ្រាសកាត់ដេរ **ចំនួន ៧៧ លើក** ។ ជាងនេះទៅទៀត, តាមរយៈវេទិកាទាំងនោះ **សម្តេចតេជោនាយករដ្ឋមន្ត្រី** តែងតែបានដោះស្រាយសំណើ ព្រមទាំងបញ្ហាប្រឈម

ទូទៅ និង ជាក់ស្តែង តាមរយៈការដាក់ចេញជាបន្តបន្ទាប់ នូវវិធានការគោលនយោបាយយ៉ាងប្រទាក់ក្រឡា សំដៅលើកកម្ពស់សុខុមាលភាព ក៏ដូចជាជីវភាពរស់នៅរបស់កម្មករ-និយោជិត និង គាំទ្រការអភិវឌ្ឍវិស័យកាត់ដេរ ។

## *ឯកឧត្តម, លោកជំទាវ, អ្នកឧកញ៉ា, ឧកញ៉ា, លោក, លោកស្រី!*

ក្នុងបរិការណ៍បច្ចុប្បន្ន, កម្ពុជាមានកាលានុវត្តភាពជាច្រើន ក្នុងការជំរុញការអភិវឌ្ឍវិស័យកាត់ដេរ ដើម្បីសម្រេចឱ្យបាន នូវការធ្វើពិពិធកម្មមូលដ្ឋានសេដ្ឋកិច្ចជាតិ ។ ក្នុងបរិបទនេះ, ការដាក់ចេញយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យនេះ គឺមានភាពចាំបាច់ និង ជាការគិតគូរជាកញ្ចប់ក្នុងក្របខណ្ឌយុទ្ធសាស្ត្រគោលនយោបាយ, ដើម្បីម្ខាង, ដោះស្រាយបញ្ហាប្រឈមដែលត្រូវបានលើកឡើងខាងលើ, ឆ្លើយតបទៅនឹងចរន្តនៃការវិវត្តថ្មីៗ, ការកើនឡើងនៃតម្រូវការទីផ្សារ និង តម្រូវការអភិវឌ្ឍន៍ក្នុងកម្រិតវិស័យទាំងមូល, និង ម្ខាងទៀត, ចាប់យកកាលានុវត្តភាពនានា សំដៅលើកកម្ពស់វិស័យនេះឱ្យចូលរួមកាន់តែល្អប្រសើរ ក្នុងការជំរុញកំណើនសេដ្ឋកិច្ចជាតិ ។

ឆ្លៀតឱកាសនេះ, ខ្ញុំសូមធ្វើការកត់សម្គាល់ពីការវិវត្តសំខាន់ៗ និង ថ្មីៗ, ទាំងក្នុងកម្រិតសកល, តំបន់ និង ក្នុងស្រុក ដែលអាចមានបច្ច័យមកលើសេដ្ឋកិច្ចជាតិ និង វិស័យកាត់ដេររបស់កម្ពុជា ដូចខាងក្រោម៖

**ទី១.** បន្ទាប់ពីកម្ពុជាសម្រេចបាននូវអត្រាចាក់វ៉ាក់សាំងខ្ពស់ដែលបង្កើតបាន នូវ «**ភាពស៊ាំសហគមន៍រឹងមាំ**» ក៏ដូចជាការបើកប្រទេស និង ការបើកសកម្មភាពសង្គម-សេដ្ឋកិច្ច ក្នុងស្រុកពេញលេញឡើងវិញ, វិស័យកាត់ដេរបានបង្ហាញនូវសញ្ញាវិជ្ជមានឡើងវិញ ។ ជាក់ស្តែង, តាមរយៈការវាយតម្លៃចុងក្រោយរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ, វិស័យកាត់ដេរអាចសម្រេចបានកំណើនល្អប្រសើរ ក្នុងអត្រា **៨,០%** ក្នុងឆ្នាំ ២០២១ ពីកំណើនធ្លាក់ចុះក្នុងអត្រា **-៦,៤%** ក្នុងឆ្នាំ ២០២០ និង រំពឹងថា នឹងសម្រេចកំណើនក្នុងរង្វង់ **៨,១%** ក្នុងឆ្នាំ ២០២២ ដែលឆ្លុះបញ្ចាំងតាមរយៈការកើនឡើងនៃតម្រូវការខាងក្រៅ ជាពិសេស ទីផ្សារសហរដ្ឋអាមេរិក គួបផ្សំនឹងការទទួលបាននូវការបង្វែរនៃការបញ្ជាទិញពីវៀតណាម និង មីយ៉ាន់ម៉ា ក្នុងពេលចំពោះមុខ ។

**ទី២.** រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញ និង ជំរុញអនុវត្ត នូវកញ្ចប់វិធានការអន្តរាគមន៍ចំនួន ១០ ជុំ ជាបន្តបន្ទាប់ ដើម្បីទ្រទ្រង់ និង ស្តារសកម្មភាពអាជីវកម្ម និង ធុរកិច្ចឱ្យងើបឡើងវិញ និង ជួយទំនុកបម្រុងដល់ជីវភាពប្រចាំថ្ងៃរបស់គ្រួសារក្រីក្រ និង ងាយរងគ្រោះ, ក្នុងនោះ, ក៏មានវិធានការអន្តរាគមន៍មួយចំនួនមានលក្ខណៈប្រទាក់ក្រឡា សំដៅជួយបណ្តារោងចក្រ-

សហគ្រាស និង កម្មករ-និយោជិត ក្នុងវិស័យកាត់ដេរ ដែលទទួលរងនូវផលប៉ះពាល់ដោយវិបត្តិជំងឺកូវីដ-១៩ ផងដែរ ។ នាពេលនេះ, វិធានការអន្តរាគមន៍សម្រាប់វិស័យកាត់ដេរនឹងត្រូវបំពេញបន្ថែម ដោយការដាក់ឱ្យអនុវត្ត នូវ **«យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកាត់ដេរ ផលិតស្បែកជើង និងកាបូបកម្ពុជា ២០២២-២០២៧»** ដែលជាយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលលើកដំបូងក្នុងក្របខណ្ឌវិស័យនេះ ។

**ទី៣.** ទោះជាយ៉ាងនេះក្តី, ការបន្តអូសបន្លាយនៃវិបត្តិជំងឺកូវីដ-១៩ តាមរយៈការបំប្លែងខ្លួននៃប្រភេទវីរុសកូរ៉ូណាថ្មីៗ, គួបផ្សំជាមួយនឹងវិបត្តិភូមិសាស្ត្រនយោបាយនាបច្ចុប្បន្ន កំពុងបន្តបង្កើត និង បង្កើនភាពមិនច្បាស់លាស់កាន់តែច្រើន ចំពោះចលនាការងើបឡើងវិញផ្នែកសង្គម-សេដ្ឋកិច្ចតំបន់ និង សកល ។ ការផ្ទុះឡើងនូវសង្គ្រាមរវាងរុស្ស៊ី និងអ៊ុយក្រែន នាពេលថ្មីៗនេះ ព្រមជាមួយនឹងការដាក់ចេញទណ្ឌកម្មសេដ្ឋកិច្ចធ្ងន់ៗមកលើរុស្ស៊ី បាន និង កំពុងបន្ទច់បង្អាក់ដល់ការងើបឡើងវិញនូវកំណើនសេដ្ឋកិច្ចសកល ជាពិសេស បង្កើនភាពមិនប្រាកដប្រជាខ្ពស់ ចំពោះការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច និង បង្កឱ្យមានការផ្លាស់ប្តូរកាន់តែហ័សនូវនិម្មាបនកម្មសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្នុងតំបន់ និង សកលលោក ដូចជា រំហូរហិរញ្ញវត្ថុ, ទុនវិនិយោគ និង ពាណិជ្ជកម្មអន្តរជាតិ និង ច្រវាក់ផ្គត់ផ្គង់ ។ល។ ជារួម, បន្ថែមលើសម្ពាធអតិផរណាពីការកើនឡើងនៃថ្លៃប្រេងក្នុងពេលចំពោះមុខ, បញ្ហាប្រឈមខាងផ្នែករចនាសម្ព័ន្ធសម្រាប់រយៈពេលមធ្យមខាងមុខ អាចនឹងធ្វើឱ្យសេដ្ឋកិច្ចកម្ពុជាទទួលរងផលប៉ះពាល់ជាអវិជ្ជមានផងដែរ ជាពិសេស អាចបង្កផលវិបាកមិនល្អ ដល់ការរីកចម្រើននៃវិស័យកាត់ដេរ តាមរយៈការថមថយនូវតម្រូវការនៃការបញ្ជាទិញផលិតផលរបស់កម្ពុជា ដែលពឹងអាស្រ័យទៅលើការនាំចេញទៅទីផ្សារអន្តរជាតិ ។

### *ឯកឧត្តម, លោកជំទាវ, អ្នកឧកញ៉ា, ឧកញ៉ា, លោក, លោកស្រី!*

ជាមួយនឹងការគិតគូរខាងលើ, ខ្ញុំសូមជម្រាបជូនអង្គពិធីឱ្យបានជ្រាបថា សេចក្តីព្រាងយុទ្ធសាស្ត្រនេះបានរៀបចំរួចរាល់ តាំងពីចុងឆ្នាំ ២០១៩ និង គ្រោងដាក់ឱ្យអនុវត្តក្នុងឆ្នាំ ២០២០ មកម្ល៉េះ, ប៉ុន្តែ ជាអកុសល ការរីករាលដាលនៃវិបត្តិជំងឺកូវីដ-១៩ បានបន្ទច់បង្អាក់ដល់ដំណើរការដាក់ឱ្យអនុវត្ត ដោយសារមានភាពចាំបាច់ ក្នុងការធ្វើបច្ចុប្បន្នភាពឯកសារនេះជាបន្តបន្ទាប់ ដើម្បីធានាសង្គតិភាព និង ឆ្លើយតបនឹងបរិបទ និង ការវិវត្តយ៉ាងលឿនលើសពីការរំពឹងក្នុងវិស័យនេះ ។

ជារួម, **«យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកាត់ដេរ ផលិតស្បែកជើង និង កាបូបកម្ពុជា ២០២២-២០២៧»** មានចក្ខុវិស័យអភិវឌ្ឍវិស័យកាត់ដេរ, ផលិតស្បែកជើង និង កាបូបនៅកម្ពុជា ឱ្យទៅជាឧស្សាហកម្មដែលមានចីរភាពបរិស្ថាន, មានភាពធន់, មានតម្លៃបន្ថែមខ្ពស់, ផ្តោតលើផលិតផលដែលលក់បានថ្លៃ, មានភាពប្រកួតប្រជែងខ្ពស់ និង ជាមូលដ្ឋានគាំទ្រពិពិធកម្មសេដ្ឋ-កិច្ចនៅឆ្នាំ ២០២៧ ។ យុទ្ធសាស្ត្រនេះក៏មានគោលបំណងកំណត់ទិសដៅអភិវឌ្ឍន៍រួម, បង្កើន ភាពឯករាជ្យ, ពង្រឹងភាពប៉ាន់ប្រមាណបាន និង ស្ថិរភាព ដើម្បីបន្តលើកកម្ពស់ការអភិវឌ្ឍ វិស័យនេះ ប្រកបដោយចីរភាព និង បរិយាប័ន្ន ។

ក្នុងន័យនេះ, ខ្ញុំសូមអនុញ្ញាតចែករំលែកនូវទស្សនាទាន និង ការចង្អុលបង្ហាញ ចំពោះកិច្ចការគន្លឹះដែលត្រូវរៀបចំបន្ត ដូចខាងក្រោម៖

**ទី១**-ការរៀបចំបង្កើតក្រុមការងារអន្តរស្ថាប័ន ទទួលបន្ទុកសម្របសម្រួលការអនុវត្តឱ្យបានឆាប់ ដើម្បីរៀបចំយន្តការស្ថាប័ន សម្រាប់តាមដានការអនុវត្តវិធានការទាំងឡាយនៅក្នុងយុទ្ធសាស្ត្រនេះ និង ពង្រឹងកិច្ចសម្របសម្រួលអន្តរស្ថាប័ន;

**ទី២**-ការបង្កើតក្រុមការងារប្រឹក្សាយោបល់វិស័យកាត់ដេរ, ផលិតស្បែកជើង និង កាបូបឱ្យបានឆាប់ ដែលមានសមាសភាពពីតំណាងវិស័យឯកជន, ដៃគូអភិវឌ្ឍន៍, ជំនាញការឯករាជ្យ, សមាគម និង សហជីព ដើម្បីផ្តល់នូវធាតុចូល និង អនុសាសន៍ សំដៅជួយគាំទ្រដល់ការអនុវត្តយុទ្ធសាស្ត្រនេះឱ្យកាន់តែមានប្រសិទ្ធភាព;

**ទី៣**-អគ្គលេខាធិការដ្ឋាន គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ (គ.ស.ហ.) និង ភាគីពាក់ព័ន្ធ ត្រូវសម្របសម្រួល និង ជំរុញការរៀបចំផែនការសកម្មភាពលម្អិត ដោយមានការចូលរួមពីក្រសួង-ស្ថាប័នទទួលបន្ទុក ស្របតាមវិធានការ និង សកម្មភាពដែលមានចែងក្នុងយុទ្ធសាស្ត្រនេះ និង

**ទី៤**-អគ្គលេខាធិការដ្ឋាន គ.ស.ហ. ត្រូវសហការជាមួយក្រសួង-ស្ថាប័នទទួលបន្ទុក និង ភាគីពាក់ព័ន្ធ រៀបចំយន្តការក្របខណ្ឌតាមដាន និង វាយតម្លៃ(M&E) ដោយមានកំណត់ច្បាស់លាស់នូវសូចនាករសមិទ្ធកម្មគន្លឹះ (KPIs) និង ក្របខណ្ឌពេលវេលាអនុវត្តជាក់លាក់ ។

***ឯកឧត្តម, លោកជំទាវ, អ្នកឧកញ៉ា, ឧកញ៉ា, លោក, លោកស្រី!***

ក្នុងទិសដៅរួមនេះ, ខ្ញុំសង្ឃឹមយ៉ាងមុតមាំថា គ្រប់តួអង្គពាក់ព័ន្ធទាំងអស់នឹងចូលរួមអនុវត្តកិច្ចការខាងលើ ដោយប្រកាន់ខ្ជាប់នូវអភិក្រមការងារ ប្រកបដោយស្មារតីបុរេសកម្ម និងការទទួលខុសត្រូវខ្ពស់ ដើម្បីធានាបាននូវភាពជោគជ័យនៃការអនុវត្តយុទ្ធសាស្ត្រនេះ ។ ជាមួយគ្នា

នេះ, គោរពតាមការចង្អុលបង្ហាញដ៏ខ្ពង់ខ្ពស់របស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី**, ខ្ញុំសូមណែនាំឱ្យអគ្គលេខាធិការដ្ឋាន គ.ស.ហ. រៀបចំខ្លួនឱ្យបានសមស្រប ដើម្បីទទួលបន្ទុកដឹកនាំសម្របសម្រួលអន្តរស្ថាប័ន ជំរុញ, តាមដាន និង ត្រួតពិនិត្យលើការអនុវត្តរាល់វិធានការ និង សកម្មភាពដែលបានដាក់ចេញក្នុងយុទ្ធសាស្ត្រនេះ ឱ្យបានប្រកបដោយប្រសិទ្ធភាពខ្ពស់ តាមការរំពឹងទុក ។

ជាថ្មីម្តងទៀត, តាងនាមឱ្យរាជរដ្ឋាភិបាលកម្ពុជា, ខ្ញុំសូមសម្តែងនូវការវាយតម្លៃខ្ពស់ និង ការកោតសរសើរ ចំពោះថ្នាក់ដឹកនាំ និង ក្រុមការងារដែលបានដឹកនាំ និង ចូលរួមរៀបចំយុទ្ធ-សាស្ត្រនេះ រហូតទទួលបានជោគជ័យ ។ ជាទីបញ្ចប់, ខ្ញុំសូមជូនពរ **ឯកឧត្តម, លោកជំទាវ, អ្នកឧកញ៉ា, ឧកញ៉ា, លោក, លោកស្រី, សមាជិក និង សមាជិកា**ទាំងអស់នៃអង្គពិធីទាំងមូល បានប្រកបដោយសុខភាពល្អ, ជៀសផុតពីជំងឺកូវីដ-១៩ និង ទទួលបានជោគជ័យក្នុងគ្រប់ភារកិច្ច ។ រូបខ្ញុំផ្ទាល់សូមសម្តែងកតញ្ញូតាធម៌ដ៏ជ្រាលជ្រៅ ជូនចំពោះ **សម្តេចអគ្គមហាសេនាបតី-តេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលជាអគ្គមហារដ្ឋបុរស និង ជាអគ្គមហាមគ្គុទេសក៍ដ៏ឆ្នើម ប្រកបដោយឆន្ទៈនយោបាយមុតស្រួច លើការងារកែ-ទម្រង់ដើម្បីអភិវឌ្ឍន៍កម្ពុជា ។ ដោយបានទទួលការអនុញ្ញាតដ៏ខ្ពង់ខ្ពស់បំផុតពីសំណាក់ **សម្តេច-អគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**, ខ្ញុំសូមប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការ នូវ «**យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកាត់ដេរ ផលិតស្បែកជើង និង កាបូបកម្ពុជា ២០២២-២០២៧**» ចាប់ពីពេលនេះតទៅ ។

*សូមអរគុណ!*